- លោកអ្នកមិនអាចយកកៅអីកង់របស់លោកអ្នកចូលទៅក្នុងបន្ទប់ប្រឡង សម្ភាសន៍ ឬ បង្គន់ ។
- បុរសច្រើនជាងស្ត្រីទទួលនូវការណែនាំឱ្យទៅហ្វឹកហ្វឺនសំរាប់ការងារដែលមានប្រាក់ខែច្រើន ។
- ខណ្ឌមិនចង់ឱ្យលោកអ្នកទទួលនូវការហ្វឹកហ្វឺន ពីព្រោះគេនិយាយថាលោកអ្នក "ចាស់ជ្រុល" ។
- គេមិនអនុញ្ញាតឱ្យលោកអ្នកសុំក្មេងមកចិញ្ចឹម ពីព្រោះតែលោកអ្នកមានជាតិសាសន៍ផ្សេង ។

## ពាក្យបណ្តឹងសំរាប់ការប្រកាន់

បើសិនជាលោកអ្នកគិតថាគេមានការប្រកាន់ចំពោះលោកអ្នកៗអាចដាក់ពាក្យបណ្តឹងដោយឡែកទៅខណ្ឌ ឬរដ្ឋ និងរដ្ឋាភិបាលសហពន្ធ ។ ក្រសួងរដ្ឋាភិបាលដែលលោកអ្នកត្រូវដាក់ពាក្យបណ្តឹងអាស្រ័យទៅលើកម្មវិធីដែលលោកអ្នកប្តឹងអំពីវា ។

លោកអ្នកអាចដាក់ពាក្យបណ្តឹងអំពីការប្រកាន់ជាមួយ :

1. សំរាប់កម្មវិធីទាំងអស់ដែលចាត់ការដោយក្រសួងសុខមាលភាពខណ្ឌរបស់លោកអ្នក :

   អ្នកសម្របសម្រួលសិទ្ធិពលរដ្ឋរបស់ខណ្ឌ (County's Civil Rights Coordinator) ។ សូមសួរការិយាល័យនៃខណ្ឌរបស់លោកអ្នកអំពីឈ្មោះ អសយដ្ឋាន និងលេខទូរស័ព្ទនៃអ្នកសម្របសម្រួលសិទ្ធិពលរដ្ឋរបស់ពួកគេ ។ លោក/អ្នកនោះនឹងធ្វើការស៊ើបអង្កេតពាក្យបណ្តឹងរបស់លោកអ្នកដោយឯករាជ្យ ។

2. Civil Rights Bureau (ការិយាល័យការពារសិទ្ធិពលរដ្ឋ)
   California Department of Social Services
   744 P Street, MS 8-16-70
   Sacramento, CA 95814
   (916) 654-2107
   (866) 741-6241 (លេខឥតបង់ប្រាក់)

3. សំរាប់កម្មវិធី CALFRESH :
   United States Department of Agriculture
   Director, Office of Civil Rights,
   Room 326-W, Whitten Bldg.
   1400 Independence Avenue, S.W.,
   Washington, D.C. 20250-9410
   (202) 720-6382 (សម្លេងនិង TTY)

4. សំរាប់កម្មវិធីដទៃទៀត:
   Health and Human Services
   Office of Civil Rights
   90 7th Street, Suite 4-100
   San Francisco, CA 94103
   (415) 437-8310 (សម្លេង)
   (415) 437-8311 (TDD)

## ពេលវេលាកំណត់សំរាប់ការធ្វើសកម្មភាព

បើសិនជាលោកអ្នករងគ្រោះដោយការប្រកាន់ លោកអ្នកត្រូវតែដាក់ពាក្យបណ្តឹងរបស់លោកអ្នកនៅក្នុងរវាង១៨០ថ្ងៃនៃការប្រកាន់ដ៏ជាក់លាក់មួយ ។ បើសិនជាការប្រកាន់នោះប៉ះពាល់ទៅដល់កំរិតនៃជំនួយនិងកិច្ចជួយរបស់លោកអ្នក លោកអ្នកក៏ត្រូវស្នើសុំសេចក្តីបំភ្លឺពីរដ្ឋមួយនៅក្នុងរវាង៩០ថ្ងៃ ។ ការស៊ើបអង្កេតអំពីការប្រកាន់មិនអាចផ្លាស់ប្តូរកំរិតជំនួយឬចំនួយជំនួយរបស់លោកអ្នកឡើយ មានតែសេចក្តីបំភ្លឺពីរដ្ឋអាចកែប្រែបាន ។

## សិទ្ធិដ៏ជាក់លាក់មានកម្រិត

ទោះបីជាលោកអ្នកមានសិទ្ធិចំពោះរឿងផ្ទាល់ខ្លួន និងជាការសម្ងាត់គឺមានច្បាប់ដ៏ជាក់លាក់មួយចំនួនដែលអនុញ្ញាតឱ្យមានការលើកលែងដែលមានកម្រិត ។ លោកអ្នកអាចសាកសួរខណ្ឌអំពីច្បាប់នេះ ។

## សំណួរ

បើសិនជាលោកអ្នកមានសំណួរអ្វីមួយអំពីសិទ្ធិនានាដូចបានចុះនៅទីនេះ សូមទូរស័ព្ទទៅការិយាល័យសាកសួរសំរាប់សាធារណៈ (Public Inquiry Unit) តាមលេខឥតបង់ប្រាក់ (800) 952-5253 ។ សំរាប់អ្នកប្រើគ្រឿងប្រដាប់ TDD តាមលេខ (800) 952-8349 ។

## កម្មវិធីដែលបាននិយាយនៅក្នុងសន្លឹកពត៌មាននេះ

- កម្មវិធីជួយទុកដាក់ក្មេងចិញ្ចឹម (Adoption Assistance Program ឬ AAP)
- កម្មវិធីការពារមនុស្សពេញវ័យ (Adult Protective Services)
- កម្មវិធីជួយអ្នកប្រមឹកនិងថ្នាំញៀន (Alcohol and Drug Program)
- កម្មវិធីជំនួយម្ហូបអាហាររដ្ឋកាលីហ្វ័រនីញ៉ា (California Food Assistance Program ឬ CFAP)
- កម្មវិធីមេឌីខាល (Medi-Cal)
- កម្មវិធី CalWORKs
- កម្មវិធីថែរក្សាក្មេងនៃ CalWORKs
- កម្មវិធី/កិច្ចជួយឱ្យចេញពីសុខមាលភាពទៅធ្វើការនៃកម្មវិធី CalWORKs (CalWORKs Welfare-to-Work)
- កម្មវិធីប្រាក់ជំនួយសំរាប់ជនអន្តោប្រវេសន៍ (Cash Assistance Program for Immigrants ឬ CAPI)
- កម្មវិធីសុខុមាលភាពក្មេង (Child Welfare Services)
- កម្មវិធី Denti-Cal
- កម្មវិធីឆែកពិនិត្យ វិភាគនិងព្យាបាលដោយមុន និងតាមពេលកំណត់ (Early & Periodic Screening, Diagnosis, and Treatment ឬ EPSDT)
- កម្មវិធី CalFresh (កម្មវិធីប័ណ្ណទិញម្ហូប (Food Stamps))
- កម្មវិធីថែរក្សាកូនចិញ្ចឹម (Foster Care)
- កម្មវិធីផ្តល់កិច្ចជួយធ្វើកិច្ចការក្នុងផ្ទះ (In-Home Support Services)
- កម្មវិធីប្រាក់ជំនួយសំរាប់ភាពជាសាច់ញាតិ–ភាពជាអ្នកអាណាព្យាបាល (Kinship Guardian Assistance ឬ Kin-GAP)
- កម្មវិធីថែរក្សាផ្នែកសតិអារម្មណ៍ (Mental Health)
- កម្មវិធីជួយចំរុះសំរាប់មនុស្សចាស់ (Multipurpose Senior Services Program ឬ MSSP)
- កម្មវិធីផ្តល់កិច្ចថែរក្សាផ្ទាល់ខ្លួន (Personal Care Services Program ឬ PCSP)
- កម្មវិធីប្រាក់ជំនួយជនភៀសខ្លួន (Refugee Cash Assistance)
- កម្មវិធីសង្គមកិច្ច (Social Services)

*STATE OF CALIFORNIA*
(រដ្ឋកាលីហ្វ័រនីញ៉ា)

*HEALTH AND HUMAN SERVICES AGENCY*
(ក្រសួងសុខភាពនិងមនុស្សភាព)

*DEPARTMENT OF SOCIAL SERVICES*
(ក្រសួងសង្គមកិច្ច)

សន្លឹកពត៌មាននេះគឺមាននៅការិយាល័យសុខមាលភាពខណ្ឌក្នុងតំបន់របស់លោកអ្នក និងតាមប្រព័ន្ធអ៊ិនធឺនិត www.cdss.ca.gov ជាភាសាដូចតទៅនេះ :

- អារ៉ាប់
- អាមេនៀន
- ខ្មែរ
- ចិន
- ហ្វាស៊ី
- ម៉ុង
- ជប៉ុន
- កូរ៉េ
- លាវ
- មៀន
- ពរទុយហ្គេ
- ពុនចាប៊ី
- រ៉ុស្ស៊ី
- អេស្ប៉ាញ៉ុល
- អេស្ប៉ាញ៉ុលជាអក្សរធំ
- តាកាឡុក
- យូក្រេនៀន
- វៀតណាម

គេក៏មានបោះពុម្ភជាអក្សរធំ អក្សរសំរាប់អ្នកពិការភ្នែក (Braille) និងស៊ីឌីសម្លេងផងដែរ ។

PUB 13 (CB) (6/11)

# សិទ្ធិរបស់លោកអ្នក

## នៅក្នុងកម្មវិធីសុខមាលភាពនៃរដ្ឋកាលីហ្វ័រនីញ៉ា



*......សំរាប់អ្នកដាក់ពាក្យសុំឬទទួលជំនួយសាធារណៈនៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា*

**សូមប្រាប់យើងបើសិនជាលោកអ្នកត្រូវការឱ្យជួយពីព្រោះមានភាពពិការមួយ**

**សូមសួររកអ្នកបកប្រែដែលផ្តល់ជូនដោយឥតគិតប្រាក់**

# សិទ្ធិរបស់លោកអ្នក

មនុស្សគ្រប់រូបនិងអង្គការដែលផ្តល់ជំនួយសាធារណៈ ត្រូវគោរពសិទ្ធិរបស់លោកអ្នក ។ ពួកគេអាចជួយលោកអ្នកឱ្យយល់និងដាក់ពាក្យសុំជំនួយ និងកិច្ចជួយនានា ។

- You have the right to an interpreter free of charge
- Usted tiene derecho a un intérprete gratis.
- У вас есть право на бесплатные услуги переводчика
- 您有權免費獲得口譯員服務。
- May karapatan kayong magkaroon ng tagapagsalin na walang bayad.
- Quý vị có quyền được một thông dịch viên miễn phí.
- Koj muaj txoj cai yuav ib tug neeg txhais lus pub dawb.
- لديك الحق في الحصول على مترجم دون أية تكلفة.
- Դուք անվճար թարգմանչի իրավունք ունեք:
- អ្នកមានសិទ្ធិទទួលអ្នកបកប្រែ ដោយមិនបាច់បង់ថ្លៃឡើយ
- 여러분은 무료 통역 서비스를 받을 권리가 있습니다.
- شما حق داشتن مترجم رايگان را دارا می باشيد.
- ທ່ານມີສິດຂໍໃຫ້ມີນາຍພາສາ ມາຊ່ວຍແປໂດຍບໍ່ເສັຽຄ່າ
- ਤੁਹਾਨੂੰ ਬਿਨਾਂ ਲਾਗਤ ਦੁਭਾਸ਼ੀਏ ਦਾ ਹੱਕ ਹੈ।
- Ви маєте право на безкоштовні послуги перекладача.
- Você tem direito a um intérprete gratuito.
- あなたには無料で通訳を利用する権利があります。
- Meih maaih leiz duqv mienh tengx meih faan waac kungx.

# លោកអ្នកមានសិទ្ធិដើម្បី...

1. យល់អំពីការសំរេចអ្វីដែលកើតមានឡើងចំពោះពាក្យដាក់សុំ និងជំនួយរបស់លោកអ្នក ។
2. ទទួលនូវការពន្យល់ជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់អំពីពាក្យដាក់សុំ និងជំនួយរបស់លោកអ្នក ។
3. ទទួលសេចក្តីចម្លងសំរាប់ឯកសារណាដែលលោកអ្នកផ្តល់ឱ្យ ។
4. ពិនិត្យមើលកំណត់ហេតុនៃសំណុំរឿងរបស់លោកអ្នក ។
5. ពិនិត្យមើលច្បាប់និងបទបញ្ញត្តិរដ្ឋ និងខណ្ឌ ។
6. ស្នើសុំឱ្យចៅក្រមពិនិត្យសាឡើងវិញលើសេចក្តីសំរេចណាមួយលើភាពអាចមានសិទ្ធិទទួលជំនួយ អំពីជំនួយ និងកិច្ចជួយនានា ។
7. មិនប្រឈមទៅនឹងការប្រកាន់ចំពោះក្នុងការទទួលជំនួយពីកម្មវិធី ឬកិច្ចជួយនានា ។
8. ដាក់ពាក្យបណ្តឹងអំពីការប្រកែរប្រកាន់ចំពាះ ។
9. ទទួលនូវកិច្ចជួយជាបន្ថែមពីបុគ្គលិកខណ្ឌដើម្បីឱ្យប្រាកដថាលោកអ្នកអាចទទួលជំនួយរបស់លោកអ្នក បើសិនជាលោកអ្នកមានភាពពិការ ឬអន់ខ្សោយវិញ្ញាណណាមួយដែលនាំឱ្យមានការពិបាកយល់ច្បាប់នៃកម្មវិធី ។
10. ពត៌មានរបស់លោកអ្នកឱ្យរក្សាទុកជាការសម្ងាត់ ។
11. ទទួលធ្វើការជូនដោយគួរសម និងគោរព ។

# បើសិនជាលោកអ្នកមានបញ្ហាជាមួយជំនួយ ឬកិច្ចជួយរបស់លោកអ្នក

1. <u>រក្សាទុកកំណត់ហេតុ</u>នៃពត៌មាន ឯកសារនានា និងការជួបជាមួយខណ្ឌទាំងអស់របស់លោកអ្នក ។
2. <u>សួររកសេចក្តីចម្លង</u>នៅពេលណាដែលលោកអ្នកផ្តល់អ្វីមួយ ។
3. លោកអ្នកអាច<u>នាំអ្នកណាម្នាក់</u>មកជាមួយលោកអ្នកទៅជួបប្រជុំជាមួយអ្នកកាន់សំណុំរឿងរបស់លោកអ្នក ។
4. <u>ដាក់ពាក្យបណ្តឹង</u> គឺមានវិធីបួនយ៉ាងដើម្បីដាក់ពាក្យបណ្តឹងនេះ :

- *ដោយក្រៅផ្លូវការ* : លោកអ្នកអាចស្នើសុំនិយាយជាមួយអ្នកត្រួតត្រាដើម្បីនិយាយអំពីបញ្ហាជាមួយអ្នកកាន់សំណុំរឿង ឬដើម្បីសាកសួរច្បាប់ឡើងវិញ និងដាក់ស្នើសកម្មភាពលើជំនួយ ឬកិច្ចជួយរបស់លោកអ្នក ។
- *សេចក្តីបំភ្លឺពីរដ្ឋ* : ស្នើសុំសេចក្តីបំភ្លឺពីរដ្ឋបើសិនជាមានបញ្ហាជាមួយជំនួយ ឬកិច្ចជួយរបស់លោកអ្នក ។ **លោកកអ្នកត្រូវតែស្នើសុំសេចក្តីបំភ្លឺនៅក្នុងរវាង៩០ថ្ងៃនៃសកម្មភាពរបស់ខណ្ឌ ។** លោកអ្នកអាចដាក់ពាក្យស្នើសុំសេចក្តីបំភ្លឺបន្ទាប់ចំនួន៩០ថ្ងៃ បើសិនជាលោកអ្នកមានមូលហេតុសមរម្យមួយ ដូចជាមានជម្ងឺ ឬភាពពិការ ។
- *ការដាក់ពាក្យបណ្តឹងសំរាប់ការប្រកាន់* : បើសិនជាលោកអ្នកគិតថាខណ្ឌប្រកាន់ចំពោះលោកអ្នក លោកអ្នកអាចដាក់ពាក្យបណ្តឹងទៅអ្នកសម្របសម្រួលសិទ្ធិពលរដ្ឋរបស់ខណ្ឌ (County's Civil Rights Coordinator) ឬទៅការិយាល័យការពារសិទ្ធិពលរដ្ឋនៃរដ្ឋ (State Civil Rights Bureau) និងទៅរដ្ឋាភិបាលសហពន្ធ (Federal Government) ។ លោកអ្នកត្រូវតែធ្វើពាក្យបណ្តឹងនេះ នៅក្នុងរយៈពេល១៨០ថ្ងៃនៃការប្រកាន់ ។ សំរាប់ពត៌មានបន្ថែម សូមអានក្នុងផ្នែកចាប់ផ្តើមពី "ការហាមប្រាមចំពោះការប្រកាន់" ។ បើសិនជាការប្រកាន់មានផលប៉ះពាល់ជំនួយ ឬកិច្ចជួយរបស់លោកអ្នក **លោកអ្នកត្រូវតែដាក់ពាក្យសុំសេចក្តីបំភ្លឺពីរដ្ឋ** បើសិនជាលោកអ្នកចង់តវ៉ាចំពោះសេចក្តីសំរេចរបស់ខណ្ឌលើជំនួយ ឬកិច្ចជួយរបស់លោកអ្នក ។
- *បណ្តឹងតវ៉ា (Grievance)* : លោកអ្នកអាចដាក់ពាក្យតវ៉ាជាមួយខណ្ឌ បើសិនជាគេមានដំណើរការតវ៉ានេះ ។ **ពាក្យបណ្តឹងតវ៉ានេះមិនការពារជំនួយរបស់លោកអ្នក** ដូចជាការស្នើសុំសេចក្តីបំភ្លឺពីរដ្ឋឡើយ ។

# សេចក្តីបំភ្លឺពីរដ្ឋ

- លោកអ្នកអាចស្នើសុំសេចក្តីបំភ្លឺពីរដ្ឋនៅពេលណាដែលលោកអ្នកមិនយល់ស្របជាមួយសកម្មភាពរបស់ខណ្ឌនៅលើជំនួយ ឬកិច្ចជួយរបស់លោកអ្នក ។
- លោកអ្នកក៏អាចស្នើសុំសេចក្តីបំភ្លឺពីរដ្ឋផងដែរ បើសិនជាខណ្ឌមិនផ្តល់ជំនួយ ឬកិច្ចជួយដែលលោកអ្នកគិតថាលោកអ្នកគួរតែបានទទួល ។
- សេចក្តីបំភ្លឺពីរដ្ឋត្រូវបានកាត់សេចក្តីដោយចៅក្រមចាត់ការផ្នែកច្បាប់នៃរដ្ឋ ។ ខណ្ឌ នឹងមានបុគ្គលិកធ្វើការម្នាក់នៅពេលធ្វើសេចក្តីបំភ្លឺដើម្បីពន្យល់ថាហេតុអ្វីបានជាគេធ្វើសេចក្តីសំរេចនោះ ។
- សេចក្តីបំភ្លឺពីរដ្ឋមិនមែនជាសេចក្តីបំភ្លឺនៅតុលាការទេ ។ លោកអ្នកអាចមានសិទ្ធិនាំអ្នកតំណាងម្នាក់ទៅជាមួយលោកអ្នក ។ គេមានជំនួយផ្នែកច្បាប់ដោយឥតគិតប្រាក់នៅគ្រប់ខណ្ឌទាំងអស់ ។ ពួកគេមានចុះនៅផ្នែកខាងក្រោយនៃសេចក្តីប្រកាសខណ្ឌរបស់លោកអ្នក ។ លោកអ្នកអាចនាំសាក្សីមកជាមួយ ។ លោកអ្នកមានសិទ្ធិទទួលអ្នកបកប្រែដោយឥតគិតប្រាក់ ។ សូមសួរខណ្ឌរបស់លោកអ្នកអំពីរបៀបទទួលអ្នកបកប្រែនេះ ។
    - បើសិនជាលោកអ្នកមានបញ្ហាជាមួយជំនួយទូទៅ (General Assistance or Genral Relief) លោកអ្នកត្រូវតែសុំសេចក្តីបំភ្លឺពីខណ្ឌ ។
    - បើសិនជាលោកអ្នកមានបញ្ហាជាមួយជំនួយសន្តិសុខសង្គ្រោះ (Social Security) លោកអ្នកត្រូវតែទាក់ទងទៅក្រសួងសន្តិសុខសង្គ្រោះ ។

# បន្តទទួលជំនួយឬកិច្ចជួយរបស់លោកអ្នក នៅរង់ចាំសេចក្តីបំភ្លឺពីរដ្ឋ

ខណ្ឌត្រូវតែផ្តល់សេចក្តីប្រកាសជូនលោកអ្នកយ៉ាងតិចណាស់១០ថ្ងៃ នៅមុនពេលសកម្មភាពណាមួយដែលបានផ្លាស់ប្តូរជំនួយ ឬកិច្ចជួយរបស់លោកអ្នកកើតមានឡើង ។ បើសិនជាលោកអ្នកស្នើសុំសេចក្តីបំភ្លឺនៅមុនពេលសកម្មភាពអនុវត្ត លោកអ្នកអាចទទួល "ជំនួយសំរាប់ពេលរង់ចាំសេចក្តីបំភ្លឺ" របស់លោកអ្នក ។ នេះគឺមានន័យថា ជំនួយរបស់លោកអ្នកនៅមានចំនួនដដែល រហូតទាល់តែលោកអ្នកទទួលសេចក្តីសំរេចនៃសេចក្តីបំភ្លឺ ។

**លោកអ្នកត្រូវតែស្នើសុំសេចក្តីបំភ្លឺមួយនៅលើសេចក្តីប្រកាសថ្មីណាដែលលោកអ្នកទទួល ដែលលោកអ្នកមិនយល់ស្រប ។**

# របៀបស្នើសុំសេចក្តីបំភ្លឺពីរដ្ឋ

1. តាមទូរស័ព្ទ : ស្នើសុំសេចក្តីបំភ្លឺពីរដ្ឋដោយទាក់ទងទៅ CA Department of Social Services តាមលេខ (800) 743-8525 ឬ (800) 952-5253
2. បំពេញនៅផ្នែកខាងក្រោយនៃសេចក្តីប្រកាស (Notice of Action ឬ NOA) របស់លោកអ្នក ឬផ្ញើសំបុត្រស្នើសុំទៅ :
   CDSS, State Hearing Division
   744 P Street M.S. 09-17-37
   Sacramento, CA 95814

# ការហាមប្រាមចំពោះការប្រកាន់

នៅក្រោមច្បាប់រដ្ឋ ក្រសួងសង្គមកិច្ចមិនអាចផ្តល់ជំនួយ ផលកម្រៃ ឬកិច្ចជួយនានាជូនលោកអ្នកដោយខុសប្លែកពីជំនួយដែលផ្តល់ជូនអ្នកដទៃទៀត ជាមូលដ្ឋានទៅលើ

*សាសន៍ ពណ៌សម្បុរ ជាតិកំណើត(ដោយគិតទាំងភាសា) ការសំគាល់ក្រុមជាតិពន្ធ អាយុ ភាពពិការ សាសនា ភេទ ចំណូលចិត្តផ្នែកភេទ អង្គការនយោបាយ ស្ថានភាពរៀបការ ឬនៅ ឬការនៅជាមួយគ្នាមិនទាន់រៀបការ ។*

ច្បាប់សហពន្ធក៏បានហាមប្រាមចំពោះការប្រកាន់មួយចំនួនដូចមាននៅខាងលើនេះដែរ ប៉ុន្តែមិនមែនទាំងអស់នេះទេ ។

ច្បាប់សហពន្ធក៏បានហាមប្រាម :

1. ពន្យារពេល ឬបដិសេធការទុកដាក់ក្មេងឱ្យគេយកទៅចិញ្ចឹមឬឱ្យទៅនៅកន្លែងយកក្មេងទៅចិញ្ចឹមជាមូលដ្ឋានទៅលើ សាសន៍ ពណ៌សម្បុរ ឬសញ្ជាតិកំណើតនៃអ្នកយកទៅចិញ្ចឹម ឬឪពុកម្តាយចិញ្ចឹម ឬចំពោះក្មេង ។
2. បដិសេធមិនឱ្យឱកាសចំពោះអ្នកណាម្នាក់ដើម្បីក្លាយទៅជាអ្នកសុំយកទៅចិញ្ចឹម ឬឪពុកម្តាយចិញ្ចឹមជាមូលដ្ឋាន ទៅលើសាសន៍ពណ៌សម្បុរ ឬសញ្ជាតិកំណើតនៃអ្នកនោះ ឬក្មេងដែលជាប់ទាក់ទង ។

# ឧទាហរណ៍នៃការប្រកាន់

- ខណ្ឌមិនផ្តល់ជូនលោកអ្នកនូវអ្នកបកប្រែដោយឥតបង់ប្រាក់ ។
- អ្នកធ្វើការប្រាប់ក្រុមជាតិពន្ធមួយអំពីកម្មវិធីនិងកិច្ចជួយច្រើនជាងពលរដ្ឋនៃជាតិពន្ធដទៃទៀត ។
- ខណ្ឌមិនជួយលោកអ្នកឱ្យទទួលកាសែតសម្លេងនៃការជំរាបអំពីកម្មវិធីជួយចំពោះលោកអ្នកដែលមានភាពពិការដែលនាំឱ្យលោកអ្នកមានការពិបាកអាន ។
- អ្នកធ្វើការដឹងអំពីសាសនា ឬអង្គការនយោបាយរបស់លោកអ្នក នឹងបានប្រព្រឹត្តចំពោះលោកអ្នកខុសប្លែកពីគេ ។
- លោកអ្នកមិនអាចទៅការណាត់ជួបរបស់លោកអ្នកបានពីព្រោះអគារនៃខណ្ឌមិនមានជណ្តើរយោង ។